

# គម្រោងស្រូវមិត្តក្រៀល

# The Crane Rice Project

ផ្តល់ចំណីបន្ថែមដល់សត្វក្រៀល សុវត្ថិភាពមនុស្ស និងអេកូឡូស៊ី

Crane supplemental food, human and ecological security



# របាយការណ៍ប្រចាំឆ្នាំ ២០២០

*លទ្ធផលសម្រេចបានសំខាន់ៗ*

ជីវិតធម្មជាតិនៅកម្ពុជា

NatureLife Cambodia

# មាតិកា


១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម............................១

២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០២០....................................................៣

២.១ ទប់ស្កាត់ការផុតពូជ ៣

២.២ អភិរក្សទីជម្រក ៤

២.៣ អភិរក្សសត្វស្លាបទេសន្តប្រវេសន៍ ១៥

២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន ១៧

២.៥ កសាងសមត្ថភាព ២១

៣. របាយការណ៍ហិរញ្ញវត្ថុ...........................................................................២៣

៤. ដៃគូ និងម្ចាស់ជំនួយ..............................................................................២៤




# ១. អង្គការជីវិតធម្មជាតិនៅកម្ពុជា៖ ចក្ខុវិស័យ និងបេសកកម្ម

អង្គការជីវិតធម្មជាតិនៅកម្ពុជាគឺជាដៃគូផ្លូវការរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិ( BirdLife International )តែមួយគត់នៅក្នុងប្រទេសកម្ពុជា។ ក្រុមប្រឹក្សាភិបាលសកលរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិបានទទួលស្គាល់អង្គការជីវិតធម្មជាតិនៅកម្ពុជាគឺជាដៃគូផ្លូវការប្រចាំកម្ពុជានាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០ព្រមទាំងចុះកិច្ចព្រមព្រាងរវាងក្រុមប្រឹក្សាភិបាលរបស់អង្គការទាំងពីរផងដែរ។

អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការក្នុងស្រុកធ្វើការផ្នែកអភិរក្សដែលបានចុះបញ្ជីជាផ្លូវការក្នុងក្រសួងមហាផ្ទៃក្នុងខែកុម្ភៈ ឆ្នាំ២០១៧។ អង្គការជីវិតធម្មជាតិនៅកម្ពុជា គឺជាអង្គការដែលមិនស្វែងរកប្រាក់កម្រៃជាឯកជន អព្យាក្រឹត មិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ និងមិនផ្តល់មធ្យោបាយជាសម្ភារ ហិរញ្ញវត្ថុ ឬធនធានមនុស្សដើម្បីគាំទ្រគណបក្សនយោបាយ ឬមនោគមវិជ្ជាណាមួយឡើយ។ អង្គការនេះត្រូវបានបង្កើតឡើងដោយមានការគាំទ្រយ៉ាងពេញទំហឹងពីអង្គការជីវិតសត្វស្លាបអន្តរជាតិក្រោមជំនួយផ្នែកហិរញ្ញវត្ថុពី មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីទទួលរងការគំរាមកំហែង (CEPF) តាមរយៈអង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN)។ អង្គការជីវិតធម្មជាតិនៅកម្ពុជាត្រូវបានបង្កើតឡើងដោយស្ថាបនិក ១២នាក់ ដែលក្នុងនោះ១០នាក់ គឺជាបុគ្គលិកស្នូលរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិប្រចាំកម្ពុជា។ ការផ្តួចផ្តើមបង្កើតនេះ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រអន្តរកាលនៃការកសាងសមត្ថភាពអង្គការក្នុងស្រុករបស់អង្គការជីវិតសត្វស្លាបអន្តរជាតិដើម្បីអាចចាប់ជាដៃគូនាពេលអនាគត (គិតមកដល់បច្ចុប្បន្នអង្គការជីវិតសត្វស្លាបអន្តរជាតិមានដៃគូចំនួន ១២១ ក្នុងបណ្តាប្រទេសនានាជុំវិញពិភពលោក)។ សមាជិកស្ថាបនិកទាំង១២នាក់ របស់អង្គការជីវិតធម្មជាតិកម្ពុជា ជឿជាក់ថា បុគ្គលិកកម្ពុជានឹងអាចអនុវត្តន៍បេសកកម្មរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិនេះបាន។



*កិច្ចប្រជុំក្រុមប្រឹក្សាភិបាលអង្គការជីវិតធម្មជាតិនៅកម្ពុជា លើកទី៥ក្នុងឆ្នាំ២០២០*

អង្គការជីវិតធម្មជាតិនៅកម្ពុជាមានចក្ខុវិស័យ បេសកកម្ម និងកម្មវិធីដូចខាងក្រោម៖

- **ចក្ខុវិស័យ** ៖ ទាំងអស់គ្នាដើម្បីរស់នៅប្រកបដោយសុខដុមរមនារវាងមនុស្ស និងធម្មជាតិ។
- **បេសកកម្ម** ៖ ធ្វើការអភិរក្សជីវៈចម្រុះតាមរយៈការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាពដើម្បីជាប្រយោជន៍របស់យើងទាំងអស់គ្នា។

និងបែងចែកជា**កម្មវិធីចំនួន៥៖**

១. ទប់ស្កាត់ការផុតពូជ

២. អភិរក្សទីជម្រក

៣. អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍

៤. លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន

៥. កសាងសមត្ថភាព

ជីវិតធម្មជាតិនៅកម្ពុជា
NatureLife Cambodia

ទប់ស្កាត់ការផុតពូជ



អភិរក្សទីជម្រក



អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍



ការលើកកម្ពស់ជីវភាពប្រជាមូលដ្ឋាន



ការបង្កើនសមត្ថភាព



# ២. លទ្ធផលសម្រេចបានប្រចាំឆ្នាំ ២០២០

## ២.១ ទប់ស្កាត់ការផុតពូជ

- ក្នុងនាមជាសមាជិកក្រុមការងារអភិរក្សសត្វត្មាតកម្ពុជា យើងបានចូលរួមផ្សព្វផ្សាយលើកកម្ពស់ការចូលរួមរបស់សាធារណជនក្នុងកិច្ចការពារអភិរក្សជិតផុតពូជបំផុតនេះតាមរយៈរៀបចំបណ្ណព័ត៌មាន និងខ្លីបវិឌីអូអប់រំខ្លីដោយផ្សព្វផ្សាយតាមប្រព័ន្ធសង្គមនាទិវាយល់ដឹងពីសត្វត្មាតអន្តរជាតិនាខែកញ្ញា ឆ្នាំ២០២០
- ចូលរួមកិច្ចប្រជុំរបស់ក្រុមការងារអភិរក្សសត្វត្មាតនៅកម្ពុជា ដើម្បីពិភាក្សា និងរៀបចំសកម្មភាពអភិរក្ស ទប់ស្កាត់កត្តាគំរាមកំហែងទៅលើសត្វត្មាត និងការអប់រំផ្សព្វផ្សាយដល់សាធារណជន។




*បណ្ណព័ត៌មានលើកកំពស់ការចូលរួមក្នុងការអភិរក្សសត្វត្មាត*

## ២.២ អភិរក្សទីជម្រក

### តំបន់ការពារទេសភាពបឹងព្រែកល្ពៅ

- បានផ្តល់ធុងសំរាមចំនួន០៣ដល់សាលាបឋមសិក្សាដែលមានមូលដ្ឋានជុំវិញតំបន់ការពារទេសភាពបឹងព្រែកល្ពៅ(មានសាលាក្ពុលជ្រុំ សាលាសង្គមមានជ័យ និងសាលាបន្ទាយផ្លាយ) ដើម្បីលើកកម្ពស់ការគ្រប់គ្រងកាកសំណល់ប្លាស្ទីក
- ផលិត និងចែកចាយផ្ទាំងព័ត៌មានដែលបរិយាយអំពីទីជម្រកសត្វក្រៀល អេកូឡូស៊ី វដ្តជីវិត និងកត្តាគំរាមកំហែងចំនួន១២សន្លឹកធំៗ ចែកចាយដល់សាលាក្ពុលជ្រុំ សាលាសង្គមមានជ័យ និងសាលាបន្ទាយផ្លាយ
- កម្មវិធីអប់រំស្តីពីសត្វក្រៀល បរិស្ថាន និងតំបន់ដីសើមសម្រាប់សាលាបឋមសិក្សាបានបញ្ចប់ឆ្នាំទី៣ ។ មេរៀនចំនួន១០ដែលបានរៀបចំចងក្រងដើម្បីបង្រៀនសម្រាប់សិក្សថ្នាក់ទី៤ ទី៥ និងទី៦ ប៉ុន្តែដោយសាលាក្ពុលជ្រុំ សាលាសង្គមមានជ័យ និងសាលាបន្ទាយផ្លាយបានបិទដោយសារមេរោគកូវីឌ១៩ មិនបានបញ្ចប់មេរៀនទាំង១០នោះទេ ដោយសាលាសង្គមមានជ័យ និងសាលាក្ពុលជ្រុំបានបញ្ចប់៨មេរៀន និងសាលាបន្ទាយផ្លាយបញ្ចប់១០មេរៀន។សរុបកុមារចំនួន២៩២នាក់(១៤៤កុមារី)បានចូលរួមកម្មវិធីអប់រំនេះ។
- លោកគ្រូ និងអ្នកគ្រូចំនួន១២នាក់ទទួលបានការបណ្តុះបណ្តាល និងឧបត្ថម្ភពីគម្រោងដើម្បីធ្វើការបង្រៀនមេរៀនដែលមានក្នុងកម្មវិធីអប់រំស្តីពីសត្វក្រៀល បរិស្ថាន និងតំបន់ដីសើម។
- រៀបចំទិវាតំបន់ដីសើមពិភពលោកក្នុងខែកុម្ភៈឆ្នាំ២០២០នាសាលាចំនួនបីគឺសាលាក្ពុលជ្រុំ សាលាសង្គមមានជ័យនិង សាលាបន្ទាយផ្លាយ។ មានអ្នកចូលរួមចំនួន៤៩៨នាក់(ក្នុងនោះមានកុមារបឋមសិក្សា លោកគ្រូ អ្នកគ្រូ នាយកសាលា អជ្ញាធរឃុំ តំណាងអង្គការ ឧទ្យានុរក្ស និងនាយករងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ)និងមានគោលបំណងលើកកម្ពស់ការចូលរួមពីអ្នកពាក់ព័ន្ធក្នុងការអភិរក្សដីសើម និងសត្វស្លាបនៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។
- ផលិត និងផ្សព្វផ្សាយសារព័ត៌មានស្តីពីផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងច្បាប់ស្តីពីតំបន់ការពារ។ គោលបំណងគឺដើម្បីបង្កើនការយល់ដឹង និងកាត់បន្ថយការទន្រ្ទានដីក្នុងតំបន់ការពារទេសភាពបឹងព្រែកល្ពៅ។
- ចូលរួមរៀបចំកិច្ចប្រជុំពិភាក្សាថ្នាក់ឃុំ និងថ្នាក់ស្រុកក្នុងការដាក់តំបន់ការពារទេសភាពបឹងព្រែកល្ពៅជាតំបន់រ៉ាមសារថ្មីរបស់ប្រទេសកម្ពុជា នៅទីរួមស្រុកកោះអណ្តែត។ កិច្ចប្រជុំបានគាំទ្រក្នុងការដាក់បញ្ចូលតំបន់ដីសើមដែលមានសារសំខាន់ជាអន្តរជាតិនេះជាតំបន់រ៉ាមសារ ប៉ុន្តែសុំអោយស្របជាមួយកិច្ចដំណើរការរៀបចំបែងចែកតំបន់គ្រប់គ្រងនៃតំបន់ការពារនេះ ដែលរៀបចំដោយក្រសួងបរិស្ថាន។




*ផ្តល់ធុងសំរាមដល់សាលាសាលាក្ពុលជ្រុំ សាលាសង្គមមានជ័យ និងសាលាបន្ទាយធ្លាយ*



*ផ្ទាំងព័ត៌មានដែលបរិយាយអំពីទីជម្រកសត្វក្រៀល អេកូឡូស៊ី វដ្តជីវិត និងកត្តាគំរាមកំហែង*



*កម្មវិធីអប់រំស្តីពីសត្វក្រៀល បរិស្ថាន និងតំបន់ដីសើមសម្រាប់សាលាបឋមសិក្សា*



*លោកគ្រូ និងអ្នកគ្រូចំនួន១២នាក់ទទួលបានការបណ្តុះបណ្តាល*



*រៀបចំទិវាតំបន់ដីសើមពិភពលោកក្នុងខែកុម្ភៈឆ្នាំ២០២០ នៅសាលាចំនួនបី*



*កិច្ចប្រជុំពិភាក្សាថ្នាក់ឃុំ និងស្រុកក្នុងការដាក់តំបន់ការពារទេសភាពបឹងព្រែកល្ពៅជាតំបន់រ៉ាមសាថ្មី របស់ប្រទេសកម្ពុជានៅទីរួមស្រុកកោះអណ្តែត*

## តំបន់ការពារទេសភាពអន្លង់ព្រីង

- ផលិត និងផ្សព្វផ្សាយសារព័តមានស្តីពីផលប៉ះពាល់អវិជ្ជមាននៃការប្រើប្រាស់ថ្នាំគីមីកសិកម្ម និងការទុកដាក់សំបកថ្នាំ មិនត្រឹមត្រូវនៅភូមិជ្រេស ភូមិកោះចម្ការ ភូមិអន្លង់ថ្ងាន់ និងភូមិព្រះទ្រហឹង ដែលមានមូលដ្ឋានស្ថិតនៅជុំវិញតំបន់ការពារទេសភាពអន្លង់ព្រីង។ គោលបំណងនៃការផ្សព្វផ្សាយនេះគឺបង្កើនចំណេះដឹង និងលើកទឹកចិត្តដល់ប្រជាសហគមន៍អោយប្រមូលសំបកថ្នាំគីមីកសិកម្មទៅទុកក្នុងធុងដែលបានកសាងដោយអង្គការជីវិតសត្វស្លាបអន្តរជាតិ។
- រៀបចំប្រជុំថ្នាក់ភូមិ នៅភូមិជ្រេសដើម្បីផ្សព្វផ្សាយបង្កើនចំណេះដឹង និងលើកទឹកចិត្តដល់ប្រជាសហគមន៍អោយប្រមូលសំបកថ្នាំគីមីកសិកម្មទៅទុកក្នុងធុងដែលបានកសាងរួចហើយ។
- រៀបចំវគ្គបណ្តុះបណ្តាលខ្លីដល់កសិករចំនួនបីភូមិគឺ ភូមិជ្រេស ភូមិកោះចម្ការ និងភូមិអន្លង់ថ្ងាន់ ស្តីពីផលប៉ះពាល់នៃការប្រើប្រាស់មិនត្រឹមត្រូវនៃថ្នាំគីមីកសិកម្ម។



វគ្គបណ្តុះបណ្តាលខ្លីដល់កសិករស្តីពីផលប៉ះពាល់នៃការប្រើប្រាស់មិនត្រឹមត្រូវនៃថ្នាំគីមីកសិកម្ម

- រៀបចំកម្មវិធីបញ្ចាំងវីឌីអូអប់រំផ្សព្វផ្សាយស្តីពីសត្វក្រៀល និងកិច្ចអភិរក្សនៅភូមិកោះចម្ការ និងភូមិកោះត្នោត។
- ផលិត និងលើកផ្លាកផ្សព្វផ្សាយស្តីពីសារសំខាន់របស់សត្វក្រៀលផ្សាភ្ជាប់ និងជីវភាពរបស់សហគមន៍បានចំនួន៣ផ្ទាំងនៅក្នុងភូមិកោះចម្ការ ភូមិអន្លង់ថ្ងាន់ និងភូមិថ្នល់

- រៀបចំទិវាតំបន់ដីសើមពិភពលោកដោយសហការជាមួយអង្គការWWT និងអង្គការជីវិតសត្វស្លាបអន្តរជាតិនៅសាលាបឋមសិក្សាថ្មបើក។ កម្មវិធីចូលរួមដោយរដ្ឋលេខាធិការក្រសួងបរិស្ថាន អគ្គរាជទូតអង់គ្លេស និងនាយកប្រតិបត្តិអង្គការWWT និងអ្នកពាក់ព័ន្ធប្រមាណជា ៥០០នាក់។ កម្មវិធីរត់ដើម្បីសត្វក្រៀល និងសកម្មភាពអប់រំផ្សេងៗជាច្រើនត្រូវបានធ្វើឡើងក្នុងទិវានេះក្នុងគោលបំណងលើកកម្ពស់ការចូលរួមពីសហគមន៍ និងអ្នកពាក់ព័ន្ធក្នុងការអភិរក្សសត្វក្រៀល និងតំបន់ដីសើម។
- អង្គការជីវិតធម្មជាតិនៅកម្ពុជាបានជួលដីចំនួន៨,៣៨៩ហិចតាពីកសិករចំនួន១២គ្រួសារបានដោយជោគជ័យដើម្បីរៀបចំកម្មវិធីសិក្សាស្រាវជ្រាវស្តីពីការដាំស្រូវសុវត្ថិភាពផ្តល់ជាចំណីបន្ថែមដល់សត្វក្រៀល(កម្មវិធីស្រូវមិត្តក្រៀល)។
- ពិធីសារកម្មវិធីសិក្សាស្រាវជ្រាវស្តីពីការដាំស្រូវសុវត្ថិភាពផ្តល់ជាចំណីបន្ថែមដល់សត្វក្រៀល (កម្មវិធីស្រូវមិត្តក្រៀល)ត្រូវបានរៀបចំ និងអនុវត្តចាប់ពី ខែកក្កដា ឆ្នាំ២០២០។ ការដាំស្រូវមានពីប្រភេទគឺ ពូជសំបកកន្ទឹម និងពូជស្រូវពងលលក ត្រូវបានធ្វើឡើងដោយកសិករចំនួន៣គ្រួសារនៅរដូវវស្សាឆ្នាំ២០២០ ដោយមិនប្រើជីគីមី។ ស្រូវ៥០%ត្រូវបានទុកអោយក្រៀលស៊ី និង៥០%ទៀតត្រូវបានច្រូត ដើម្បីទុកពូជ និងលក់អោយអ្នកស្រឡាញ់សត្វស្លាប និងធម្មជាតិក្រោមយីហោថ្មីមានឈ្មោះថាអង្ករមិត្តក្រៀល។
- ព្រុំប្រទល់ និងផ្ទាំងព័ត៌មានស្តីពីស្រូវមិត្តក្រៀលចំនួន១៧ផ្លាក ត្រូវបានលើកជុំវិញស្រែមិត្តក្រៀល និងនៅក្នុងភូមិ។
- យីហោអង្ករមិត្តក្រៀលត្រូវបានរចនា និងបោះពុម្ពលើសំភារៈវេចខ្ចប់ និងគំនិតផ្តួចផ្តើមស្រូវឬអង្ករមិត្តក្រៀលនេះត្រូវបានគាំទ្រ និងឯកភាពដោយរដ្ឋមន្ត្រីក្រសួងបរិស្ថាន។



*រៀបចំកម្មវិធីបញ្ចាំងវីឌីអូអប់រំផ្សព្វផ្សាយស្តីពីសត្វក្រៀល និងកិច្ចអភិរក្ស*



*រៀបចំទិវាតំបន់ដីសើមពិភពលោកដោយសហការជាមួយអង្គការWWT និងអង្គការជីវិតសត្វស្លាបអន្តរជាតិនៅសាលាបឋមសិក្សាថ្មបើក*




*លើកផ្លាកផ្សព្វផ្សាយស្តីពីសារសំខាន់របស់សត្វក្រៀលផ្សាភ្ជាប់ និងជីវភាពរបស់សហគមន៍*




*ជួលដីចំនួន៨,៣៨៩ហិចតាពីកសិករចំនួន១២គ្រួសារ*


NatureLife Cambodia

BirdLife INTERNATIONAL CAMBODIA PROGRAMME

IUCN National Committee of The Netherlands

**A Protocol of Crane Friendly Rice**

**Enhancing food and ecological security for human and cranes**



**Yav Net**

Project Coordinator, NatureLife Cambodia

December, 2020

*ពិធីសារកម្មវិធីសិក្សាស្រាវជ្រាវស្តីពីការដាំស្រូវសុវត្ថិភាពផ្តល់ជាចំណីបន្ថែមដល់សត្វក្រៀល*



*ការដាំស្រូវ សំបកកន្ទឹម និងពងលលកដោយកសិករចំនួន៣គ្រួសារនៅទីតាំងដីដួល*









*ព្រំប្រទល់ និងផ្ទាំងព័ត៌មានស្តីពីស្រូវមិត្តក្រៀលចំនួន១៧ផ្លាកត្រូវបានដំឡើង*



*ឃើហោអង្កុរមិត្តក្រៀលត្រូវបានរចនា និងបោះពុម្ពលើសំការៈវេចកញ្ចប់*

## តំបន់រ៉ាមសារស្ទឹងសែន

- អង្គការជីវិតធម្មជាតិនៅកម្ពុជាបានទទួលថវិកាពីមូលនិធិCEPFក្នុងការចូលរួមសហការនិងទទួលភារកិច្ចបន្តពីអង្គការជីវិតសត្វស្លាបអន្តរជាតិក្នុងកិច្ចគាំទ្រដល់ឧទ្យានុរក្សក្នុងការល្បាតអនុវត្តច្បាប់ និងអង្កេតតាមដានជីវៈចម្រុះចាប់ពីខែកក្កដា ឆ្នាំ២០២០មក។
- ការសិក្សាពីតម្រូវការកសាងសមត្ថភាពត្រូវបានរៀបចំឡើងសម្រាប់ឧទ្យានុរក្សតំបន់រ៉ាមសារស្ទឹងសែន និងបុគ្គលិកអង្គការជីវិតធម្មជាតិនៅកម្ពុជាដើម្បីធ្វើការគ្រប់គ្រង និងអង្កេតតាមដានជីវៈចម្រុះនៅតំបន់រ៉ាមសារនេះអោយកាន់តែមានប្រសិទ្ធភាព
- ឧបករណ៍ R-METTត្រូវបានប្រើប្រាស់ដើម្បីប្រមូលព័ត៌មានបឋមស្តីពីប្រសិទ្ធភាពនៃការគ្រប់គ្រងតំបន់រ៉ាមសារស្ទឹងសែន
- អង្គការជីវិតធម្មជាតិនៅកម្ពុជាបានចាប់ផ្តើមគាំទ្រដល់ការល្បាតរបស់ឧទ្យានុរក្សក្នុងការបង្ក្រាបបទល្មើស និងអង្កេតតាមដានជីវៈចម្រុះ។ ការនេសាទ និងការទន្ទ្រានដីខុសច្បាប់ជាច្រើនករណីត្រូវបានបង្ក្រាប ការដកហូត និងបំផ្លាញវត្ថុល្មើស។ សត្វស្លាប៦០ប្រភេទត្រូវបានកត់ត្រាក្នុងនោះមាន៥ប្រភេទ ជាប្រភេទទទួលរងការគំរាមកំហែងជាសកលដូចជាត្រដក់តូច ស្មោញ ទុងប្រផេះ អកត្រីក្បាលប្រផះ ទនាលពណ៌ជាដើម។



*ឧទ្យានុរក្សល្បាតប្រចាំខែ*

- ការបណ្តុះបណ្តាលស្តីពីការប្រើប្រាស់GPS ផែនទី និងសារសំខាន់នៃព្រៃលិចទឹកត្រូវបានរៀបចំសម្រាប់ឧទ្យានុរក្សស្ទឹងសែន និងបង្រៀនដោយបុគ្គលិកបច្ចេកទេសរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិ។
- ដំណើរទស្សនកិច្ចសិក្សសម្រាប់ឧទ្យានុរក្សតំបន់ការពារទេសភាពបឹងព្រែកល្ពៅត្រូវបានរៀបចំឡើងក្នុងខែកញ្ញា ឆ្នាំ២០២០ ក្នុងគោលបំណងដកស្រង់បទពិសោធន៍ពីការងារគ្រប់គ្រងតំបន់ដីសើម និងបង្កើនកិច្ចទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ។



*ទស្សនៈកិច្ចសិក្សាទៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ*



*សត្វទុងប្រផេះដែលកត់ត្រាក្នុងពេលល្បាត*

## ២.៣ អភិរក្សសត្វស្លាបទេសន្តរប្រវេសន៍

- អង្គការជិវិតធម្មជាតិទទួលមូលនិធិពីOriental Bird Club ដើម្បីធ្វើការសិក្សាស្រាវជ្រាវពីសត្វស្លាបទេសន្តរប្រវេសន៍នៅតាមឆ្នេរក្នុងខេត្តកែប និងកំពត។ ការសិក្សនេះនឹងចាប់ផ្តើមក្នុងខែមករាឆ្នាំ២០២១។
- ការចូលរួមរៀបចំទិវាសត្វស្លាបទេសន្តរប្រវេសន៍ ឆ្នាំ២០២០ នៅមុខសាលមហោស្រពខេត្តតាកែវ ក្នុងគោលបំណងលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋដល់កិច្ចការពារ និងអភិរក្សសត្វស្លាបទេសន្តប្រវេសន៍ដែលកំពុងរងគ្រោះដូចសត្វក្រៀលជាដើម។ កម្មវិធីអប់រំផ្សព្វផ្សាយនេះប្រព្រឹត្តិឡើងក្រោមអធិបតីភាពឯកឧត្តម ទា ផុប រដ្ឋលេខាធិការនៃក្រសួងបរិស្ថាន ឯកឧត្តមអភិបាលរងខេត្តតាកែវ លោកបណ្ឌិតប្រធាននាយកដ្ឋានអភិរក្សតំបន់ដីសើមទឹកសាប ប្រធានមន្ទីរបរិស្ថានខេត្តតាកែវ អ្នកសម្រេសសម្រួលប្រចាំប្រទេសកម្ពុជាអង្គការWWT ព្រមទាំងមានការចូលរួមពីមន្ទីរពាក់ព័ន្ធ អង្គការដៃគូ និងសិស្សានុសិស្សមកពីសាលារៀនចំនួនបីនៅខេត្តតាកែវ។ នៅក្នុងឱកាសនេះឯកឧត្តមរដ្ឋលេខាធិការបានសំណូមពរដល់ប្រជាពលរដ្ឋ និងសិស្សានុសិស្សទាំងអស់ ត្រូវចេះស្រលាញ់ ថែរក្សា និងការពារសត្វស្លាបគ្រប់ប្រភេទ ដែលមានវត្តមាននៅប្រទេសកម្ពុជាសម្រាប់កូនចៅជំនាន់ក្រោយៗរបស់យើងអោយបានស្គាល់ពីភាពសម្បូរបែបនៃប្រភេទសត្វរបស់កម្ពុជាយើង។ ឯកឧត្តមបានប្រគល់សត្វក្រៀលមួយគូ ដែលឪហ្សាញដោយអង្គការជីវិតស្លាបអន្តរជាតិជូនដល់រដ្ឋបាលខេត្តតាកែវដើម្បីដាក់តាំងក្នុងសួនសាធារណៈ និងជាសក្ខីភាពនៃការខិតខំប្រឹងប្រែងរបស់យើងទាំងអស់គ្នាដើម្បីការពារ

ប្រភេទសត្វកម្រនេះដែលមានវត្តមានជាប្រចាំចាប់ពីខែធ្នូដល់ខែកុម្ភៈ នៅតំបន់ការពារទេសភាពបឹងព្រែកល្ពៅ ដែលស្ថិតនៅស្រុកបូរីជលសារ និងកោះអណ្តែត នៃខេត្តតាកែវ។



*ទិវាសត្វស្លាបទេសន្តរប្រវេសន៍ ឆ្នាំ២០២០*




*ទិវាសត្វស្លាបទេសន្តរប្រវេសន៍ ឆ្នាំ២០២០*



*សត្វក្រៀលមួយគូដាក់តាំងក្នុងសួនច្បារសាធារណៈ*

## ២.៤ លើកកម្ពស់ជីវភាព និងបង្កើនការចូលរួមពីប្រជាមូលដ្ឋាន

ចូលរួមរៀបចំកម្មវិធីទិវាតំបន់ដីសើមពិភពលោក ឆ្នាំ២០២០ ក្រោមប្រធានបទ តំបន់ដីសើម និងជីវៈចម្រុះ ដែលចូលរួមក្នុងការលើកម្ពស់ការយល់ដឹង និងការអភិរក្សតំបន់ដីសើមពីសហគមន៍មូលដ្ឋាន។

**ការជំរុញការចូលរួមរបស់សហគមន៍ក្នុងការគ្រប់គ្រង និងប្រើប្រាស់តំបន់រ៉ាមសារស្ទឹងសែន**

**ការពង្រឹងសមត្ថភាពសហគមន៍តំបន់ការពារធម្មជាតិទូលនាងសារផ្លូវហ្លួង**

- ប្រជុំសិក្សាពីស្ថានភាពបច្ចុប្បន្នរបស់គណៈកម្មការ និងលក្ខខ័ណ្ឌផ្លូវច្បាប់របស់សហគមន៍នេះ
- គាំទ្រដល់មន្ទីរបរិស្ថាន និងសមាជិកសហគមន៍នេះក្នុងការបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីមួយជំនួសគណៈកម្មការចាស់ដែលផុតអាណត្តិ។ គណៈកម្មការ០៩នាក់ត្រូវបានជ្រើសរើស និងប្រធានសហគមន៍គឺជាស្ត្រី(លោកស្រី ហ៊ីន ឆេងគា) និងមានដេការឃុំផាត់សណ្ដាយទទួលស្គាល់ជាផ្លូវការ។
- ធ្វើបច្ចុប្បន្នភាពសមាជិករបស់សហគមន៍ដោយមានសមាជិក ១៣៦គ្រួសារបានដាក់ពាក្យចូលជាសមាជិក។
- លក្ខន្តិកៈរបស់សហគមន៍ត្រូវបានធ្វើវិសោធនកម្មតាមលទ្ធផលនៃការបោះឆ្នោត ជ្រើសរើសគណៈកម្មការថ្មី និងបានទទួលការគាំទ្រពីអជ្ញាធរឃុំ

- ការសិក្សាពីសេដ្ឋកិច្ចសង្គមត្រូវបានធ្វើឡើងដើម្បីរៀបចំផែនការគ្រប់គ្រងសហគមន៍នេះ
- ពិធិសារក្នុងការល្បាត និងតាមដានជីវៈចម្រុះនៃសហគមន៍នេះត្រូវបានរៀបចំ និងយកមកអនុវត្តចាប់ពីខែវិច្ឆការឆ្នាំ២០២០
- សំភារមួយចំនួនដូចជាទូកម៉ាស៊ីន GPS កែវយឺត ថ្មពិល ផែនទី កញ្ចប់សង្គ្រោះបន្ទាន់ត្រូវបានផ្តល់ដល់គណៈកម្មសហគមន៍ដើម្បីប្រើប្រាស់ក្នុងការល្បាត
- បណ្តុះបណ្តាលសហគមន៍ស្តីពីការប្រើប្រាស់ GPS កែវយឹត ការប្រមូលទិន្នន័យជីវៈចម្រុះ និងការធ្វើរបាយការណ៍ ដោយឡែកប្រធានសហគមន៍ បានបណ្តុះបណ្តាល និងលើកទឹកចិត្តក្នុងការចូលរួមប្រជុំបញ្ចេញមតិក្នុងវេទការសហគមន៍នានា។
- គណៈកម្មការសហគមន៍ធ្វើការល្បាតតាមពិធីសារចាប់ពីខែវិច្ឆការ ដោយមានការគាំទ្រអាហារ និងប្រេងឥន្ធនៈពីអង្គការ។ ការនេសាទ និងការទន្ទ្រានដីជាបទល្មើសដែលសហគមន៍នេះកំពុងប្រឈម។

**ការបង្កើតតំបន់សហគមន៍ថ្មី**

- កិច្ចប្រជុំពិភាក្សាជាមួយមេភូមិទាំង០៥ មេឃុំ ផាត់សណ្តាយ នាយកតំបន់រ៉ាមសារ និងតំណាងមន្ទីរបរិស្ថានកំពង់ធំត្រូវបានរៀបចំ។ អង្គប្រជុំឯកភាពក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីមួយទៀតតែត្រូវធ្វើស្របគ្នាជាមួយសកម្មភាពបែងចែកតំបន់គ្រប់គ្រងស្ទឹងសែនដែលកំពុងដឹកនាំធ្វើដោយក្រសួងបរិស្ថាន។



*គណៈកម្មការ០៩នាក់ ត្រូវបានជ្រើសរើស និងប្រធានសហគមន៍គឺជាស្ត្រី( លោកស្រី ហ៊ីន ឆេតា) និងមានដេការឃុំផាត់សណ្តាយទទួលស្គាល់ជាផ្លូវការ*



*ការប្រគល់ជូន GPS និងកែវយឺត ដល់សហគមន៍*



*សហគមន៍ល្បាតប្រចាំខែ*




*ប្រគល់ទូកមានម៉ាស៊ីន ដល់សហគមន៍*



*បណ្តុះបណ្តាលសហគមន៍ស្តីពីការប្រើប្រាស់ GPS កែវយឹត ការប្រមូលទិន្នន័យជីវៈចម្រុះ និងការធ្វើរបាយការណ៍*



*អង្គប្រជុំឯកភាពក្នុងការបង្កើតសហគមន៍តំបន់ការពារធម្មជាតិថ្មីមួយទៀត*

## ២.៥ កសាងសមត្ថភាព

- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជាប្រចាំឆមាស និងប្រចាំឆ្នាំ
- រៀបចំកិច្ចប្រជុំគណៈកម្មការប្រតិបត្តិរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជាប្រចាំខែ
- ចូលរួមប្រជុំជាមួយគណកៈម្មការជ្រើសរើសអង្គការដៃគូរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិ
- បំពេញបែបបទក្នុងការស្នើរសុំចូលជាដៃគូផ្លូវការរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិ
- ក្រុមប្រឹក្សាភិបាលសកលរបស់អង្គការជីវិតសត្វស្លាបអន្តរជាតិបានប្រជុំ និងសម្រេចទទួលស្គាល់អង្គការជីវិតធម្មជាតិនៅកម្ពុជាគឺជាដៃគូផ្លូវការប្រចាំកម្ពុជានាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២០
- កិច្ចព្រមព្រាងជាដៃគូរវាងអង្គការជីវិតសត្វស្លាបអន្តរជាតិ និងអង្គការជីវិតធម្មជាតិនៅកម្ពុជាត្រូវបានចុះហត្ថលេខារវាងក្រុមប្រឹក្សាភិបាលរបស់អង្គការទាំងពីរ។
- ជ្រើសរើសបុគ្គលិកថ្មីតាមតម្រូវការរបស់គម្រោងបុគ្គលិកអង្គការបានកើនពី៣ទៅ៦នាក់
- អង្គការជីវិតធម្មជាតិនៅកម្ពុជាត្រូវបានជ្រើសរើសជាដៃគូរបស់គម្រោងកសាងសមត្ថភាពរបស់USAID ដែលមានឈ្មោះថា "Movement Towards Self Reliance Activity"(LO-MTSR)។ គម្រោងនេះបានវាយតំលៃ និងរៀបចំផែនការបង្កើនសមត្ថភាពសំរាប់អង្គការជីវិត

ធម្មជាតិលើផ្នែកស្វែងរកថវិកា យុទ្ធសាស្រ្តទំនាក់ទំនង ការផ្សព្វផ្សាយពីអង្គភាពជាដើម។ វគ្គបណ្តុះបណ្តាល និងធ្វើឡើងក្នុងឆ្នាំ២០២១។



*ប្រជុំក្រុមប្រឹក្សាភិបាលរបស់អង្គការជីវិតធម្មជាតិនៅកម្ពុជាប្រចាំឆមាស*




*គណកម្មការអង្គការBirdLife International សំរាប់គាំទ្រ*
*និងជ្រើសរើសដៃគូនៅកម្ពុជា*

# ៣. របាយការណ៍ហិរញ្ញវត្ថុ

**របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០**

| | 2020 US$ |
|---|---|
| **ចំណូល** | |
| ចំណូលទទួលបានពីម្ចាស់ជំនួយ | 42977.78 |
| វិភាគទានពីម្ចាស់ជំនួយឯកជន | 0.00 |
| ចំណូលផ្សេងៗ | 10.00 |
| | **42987.78** |
| **ចំណាយ** | |
| ចំណាយលើបុគ្គលិក | 7042.05 |
| សម្ភារៈការិយាល័យ/សម្ភារៈ/ឧបករណ៍ប្រើប្រាស់ | 380.90 |
| ទូរគមនាគមន៍ / ប៉ុស្ដិ៍ / អ៊ិនធឺណិត | 718.29 |
| ការងារអភិរក្ស និងសហគមន៍ | 33690.79 |
| សិក្ខាសាលា / កិច្ចប្រជុំ | 3019.72 |
| ឧបករណ៍និងសម្ភារៈផ្គត់ផ្គង់ | 3358.17 |
| ការធ្វើដំណើរ | 3853.86 |
| ចំណាយប្រយោល | 205.88 |
| ការផ្តល់ជំនួយបន្ត | 9568.57 |
| | **61838.23** |
| **ការទូទាត់ចំណូល និងចំណាយ** | **(18850.45)** |
| **សមតុល្យពីឆ្នាំមុន** | **75,324.07** |
| **សមតុល្យបំណាច់ឆ្នាំ២០២០** | **56473.62** |

# ៤. ដៃគូ និងម្ចាស់ជំនួយ

## ស្ថាប័នរដ្ឋ

## អង្គការដៃគូ និងក្រុមការងារ

## ម្ចាស់ជំនួយ



**អង្គការជីវិតធម្មជាតិនៅកម្ពុជា/NatureLife Cambodia**
រតនគិរី៖ ផ្ទះលេខ៣៥ ផ្លូវលេខ៣៣ ភូមិអូរកន្ធិល សង្កាត់បឹងកន្សែង ក្រុងបានលុង ខេត្តរតន គិរី
ភ្នំពេញ៖ ផ្ទះលេខ៣២A សង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ
អ៊ីម៉ែល៖ admin@naturelifecambodia.org
គេហទំព័រ ៖ www.naturelifecambodia.org
លេខទំនាក់ទំនង៖ ០៧៨ ៧៣២ ២៤០ ឬ ០២៣ ៩៩៣ ៦៣១